## រាជធានីភ្នំពេញ៖ លោក សួន សេរីរដ្ឋា ប្រធានគណបក្សអំណាចខ្មែរ ប្រតិកម្មទៅនិង លោក ហ៊ុន សែន និយាយថា ប្រសិនបើគណបក្សសង្គ្រោះជាតិឈ្នះឆ្នោតនឹង មានសង្គ្រាម

(ថ្ងៃទី21 ខែតុលា ឆ្នាំ2015 ម៉ោង 17:45)

0

កាលពីថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ នៅក្នុងពិធីចែកសញ្ញាបត្រដល់និស្សិតនៅវិទ្យាស្ថានជាតិអប់រំ លោកហ៊ុន សែន បានប្រកាសសាជាថ្មីថា សង្គ្រាមត្រូវតែកើតឡើងពិតប្រាកដមែនប្រសិនបើបក្សសង្គ្រោះជាតិឈ្នះការបោះឆ្នោត ។

នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ នៅទីស្នាក់ការបក្សអំណាចខ្មែរ មានធ្វើសន្និសីទកាសែតមួយ លោក សួន សេរីរដ្ឋា ប្រធានគណបក្សអំណាចខ្មែរ បានប្រតិកម្មទៅនិង លោក ហ៊ុន សែន ដែលលើកឡើងថា នឹង មានសង្គ្រាមកើតឡើង ប្រសិនបើគណបក្សសង្គ្រោះជាតិឈ្នះឆ្នោត ។

ថ្លែងទៅកាន់ក្រុមអ្នកសារព័ត៌មាន លោក សួន សេរីរដ្ឋា ប្រធានគណបក្សអំណាចខ្មែរ បានប្រតិកម្មនឹង លោក ហ៊ុន សែន ថា ការលើកឡើងតែពីបញ្ហាសង្គ្រាមមកបំភ័យសតិអារម្មណ៍ប្រជាពលរដ្ឋ គឺជាការប្រមាថដល់អាយុជីវិតប្រទេសជាតិរបស់ខ្លួន និង អាចបញ្ឈប់អ្នកវិនិយោគបរទេស ឲ្យឈប់មករកស៊ីនៅកម្ពុជាផងដែរ ។

លោក សួន សេរីរដ្ឋា បន្តទៀតថា ពួកអ្នកវិនិយោគទុនបរទេស ឬ អ្នកជំនួញសុចរិតទាំងឡាយ នឹងមិនមករកស៊ីនៅក្នុងប្រទេសខ្មែរឡើយ ប្រសិនបើអ្នកដឹកនាំគម្រាមតែពីរឿងសង្គ្រាមដូច្នេះ ការដែល មិនមានអ្នកជំនួញបរទេសចូល មករកស៊ីនៅស្រុកខ្មែរ គឺ ជាផលប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ប្រទេសទាំងមូល ហើយថែមទាំង ចាត់ទុកលោក ហ៊ុន សែន ថាជាមេដឹកនាំបែបឈ្មួញសង្គ្រាមទៀតផង ។

លោកបញ្ជាក់បែបនេះថាអ្នកដឹកនាំជាឈ្មួញសង្គ្រាម មិនចេះអ្វីក្រៅពីសង្គ្រាមទេ ព្រោះមានតែសង្គ្រាមប៉ុណ្ណោះ ទើបអាចការពារអំណាចរបស់ខ្លួនបាន យើងដឹងហើយថា អត់មានភាគីណា អត់មានគណបក្សណាមានកងទ័ពទេ គណបក្សដែលមានកងទ័ព ឧត្ុ្តមសេនីយ៍ ច្រើនជាងគេ ក្តោបក្តាប់ កងទ័ព នគរបាល គឺ គណបក្សប្រជាជនកម្ពុជា ។

កន្លងមក ក្រុមអ្នកវិភាគ និង អ្នកតាមដានស្ថានការណ៍នយោបាយមួយចំនួនបានរិះគន់ចំពោះ សារនយោបាយរបស់លោក ហ៊ុន សែន ដែលតែងតែគម្រាមម្តងហើយម្តងទៀត ពី ការផ្ទុះសង្គ្រាមនេះ៕

- See more at: http://www.dpn-news.com/article.php?id=868&sec_id=9#.VinGTtd9ZI4.facebook